Le raisonnement commence à partir du moment où l'élève s'efforce de comprendre l'énoncé d'un problème jusqu'à la phase finale de la résolution. Dès que l'invention a découvert la voie de la solution, le raisonnement intervient pour la justifier, pour la développer pas à pas

Cette marche logique en avant part des hypothèses et, de déduction en déduction, arrive à la conclusion. En mathématiques, il est nécessaire que les hypothèses restent immuables pendant toute la démonstration, sans quoi le raisonnement se trouve faussé dans sa progression. Dans les démonstrations géométriques, il est recommandé de numéroter les hypothèses, pour en prendre conscience plus nettement, et surtout pour contrôler si ces hypothèses ont été toutes utilisées pendant la démonstration. Il y a des élèves qui introduisent, sciemment ou inconsciemment, de nouvelles hypothèses, croyant que le sujet est incomplet ou pas assez explicite. D'autres se trouvent influencés par la conclusion et l'introduisent sans le savoir dans le corps de la démonstration, au lieu d'y aboutir.

Le plus difficile, pour le professeur de mathématiques, c'est de convaincre l'élève que son raisonnement « ne tient pas debout » parce que les matériaux avec quoi il le battit « ne collent pas » Il faut montrer la fragilité de l'édifice à son auteur et aux autres, en démontant un par un les matériaux et leur faire voir en quoi réside l'erreur du raisonnemnt. Les bons élèves ne se rendent pas du premier coup à la logique du maître, ils défendent âprement leur logique à eux. C'est bon signe, mettons-y beaucoup de temps et de patience et nous les formerons à la rigueur du raisonnement mathématique.

## VI. FAIRE ATTENTION

L'attention est nécessaire aussi bien pour comprendre et juger l'énoncé d'un problème, que pour la recherche de la solution. L'attention peut être spontanée ou réfléchie exigeant un effort de concentration.

L'élève distrait est souvent celui qui ne prend aucun intérêt à son travail, ou s'il tente de s'y intéresser, son attention ne peut être soutenue et se trouve vite détournée par des causes extérieures. Mais il n'est pas forcément paresseux

L'élève étourdi commet des erreurs par précipitation. Son attention, trop hâtive, ne peut contrôler tous les points importants et en laisser échapper. Son défaut est pourtant moins grave que la distraction.

Pour nous, l'élève se prête aux efforts d'attention, s'il y trouve son intérêt. Inversement en l'obligeant à exécuter un travail attentivement, l'élève y découvre quelque intérêt et finit par s'y absorber entièrement.

Dans le domaine mathématique l'attention peut être cultivée de diverses façons. Un moyen est indiqué par Michel Margot : il consiste à habituer les élèves à l'attention volontaire de courte durée. Il fait lire l'énoncé d'un problème une seule fois, mais très attentivement puis

il fait fermer le livre. Les élèves en ont été avertis. Après, il les oblige à reconstituer mentalement le sujet, en leur faisant raconter à leur façon, même en oubliant les valeurs numériques des données. On devine combien leur attention est mise à l'épreuve pour retenir du premier coup toutes les données statiques du sujet et saisir en même temps les relations entre ces données.

*
* *

Au terme de cette étude, nous pouvons grouper les six activités mentales de la façon suivante :

**Comprendre, juger, assimiler** intéressent la phase de prise de conscience des données statiques du sujet.

**Inventer** et **raisonner** intéressent la phase de l'action, la phase opératoire.

Quant à l'**attention**, elle est l'élément indispensable d'efficacité à tous les stades d'activités précédentes.

Le professeur de mathématiques qui se double du psychologue voit, dans chaque sujet proposé aux élèves, lesquelles de ces activités doivent intervenir au cours de l'élaboration mathématique et laquelle qui prédomine. Nous avons vu que les problèmes d'algèbre exigeant le choix d'une ou de plusieurs inconnues et la mise en équation, sont très propices pour développer le jugement de relation. Nous regrettons que depuis quelque temps, les exercices d'algèbre proposés au **D.E.S.P.C** sont des exercices de calcul algèbrique pur obligeant seulement les élèves à un travail mécanique, mais ne faisant intervenir que très peu les activités «juger», «inventer», «raisonner». Ils n'exigent que l'attention pour éviter les étourderies pendant le calcul. Bien entendu, le travail de correction se trouve très facilité, parce qu'il ne faut regarder principalement que les réponses pour noter.

Au cours de l'explication de l'énoncé d'un problème, ou de la correction des devoirs, le professeur averti s'aperçoit aisément de la déficience de certaines de ces activités, chez ses élèves. Nous en rencontrons qui sont forts en algèbre mais qui éprouvent de grandes difficultés en géométrie. Pourquoi? parce qu'en algèbre, l'élaboration mathématique s'adresse surtout à l'activité « juger », tandis qu'en géométrie il faut souvent «inventer», point faible de ces élèves Le professeur averti peut confectionner des sujets à la mesure des élèves particuliers dont il connaît les déficiences. Nous sommes là en face d'une pédagogie curative.

**CIRCULAIRE DU MINISTÈRE de l'Education Nationale (28 janvier 1966)**

# A PROPOS DES LOISIRS

J'ai l'honneur de vous faire connaître que lors des dernières vacances, et aussi, d'après des rapports recueillis, une bonne mojorité d'Etablissements scolaires du Royaume ont effectué des sorties, excursions et visites instructives à l'issue desquelles, nos jeunes ont tiré de grands profits.

Certains Etablissements et Ecoles ont organisé les voyages par cars, autobus, chaloupes. Certains d'autres se déplacent à bicyclette. Les modestes vont à pieds. Et tous s'envolaient le cœur plein de gaieté. Ils ont visité les richesses du pays, ainsi que les réalisations du Sangkum Reastr Niyum qui se trouvent sur leur passage. Et d'après les informations reçues, nos Scolaires et Universitaires ont trouvé un accueil très encourageant auprès des autorités locales, des Directeurs des Entreprises ou des Usines et des Fonctionnaires Techniques qui ne ménagent aucun effort pour satisfaire leur curiosité par des exposés ou des explications aux questions posées Ils ont pu, par ce procédé, voir du nouveau et constater de leurs propres yeux ce qu'ils ont entendu et appris. Ils ont pu, par ces sorties, se mettre en contact direct avec la nature et mener une vie en commun avec leurs camarades pour mieux les connaître et les apprécier. Ils ont également rapporté après cette courte randonnée un riche bagage de connaissances de la vie économique, agricole, industrielle et sociale de la Nation. Ils ont goûté la fraîcheur et la beauté de nos stations et sites souventes fois chantés par des touristes étrangers. Ils ont vraiment touché du doigt de ce que le Sangkum Reastr Niyum sous l'égide éclairé de SAMDECH SAHACHIVIN a réalisé depuis 10 ans et qui fait la fierté du Cambodge.

En somme, ces activités instructives ont donné des résultats fort louables aussi bien au point de la formation directe de l'esprit qu'à celui du corps.

Aussi vous demanderais-je de vouloir bien envisager la possibilité d'organiser **au moins une fois par mois** des sorties à l'intention de nos jeunes. Elles pourraient être des travaux manuels pour le bien du public, la propreté des jardins ou des places publiques, des visites ou excursions des entreprises, centres agricoles environnants etc . . .

Je compte fermement sur votre esprit d'initiative et sur votre précieuse collaboration pour lancer ces activités afin qu'elles deviennent une habitude de l'Etablissement et dont l'intérêt est incontestablement très grand.

Je recommande particulièrement aux dirigeants de la JSRK de veiller et d'observer pendant ces sorties des règles strictes de notre mouvement, de donner des instructions précises avant la sortie et veiller à la sécurité des jeunes.

Je serais très heureux de recevoir sous peu votre **plan d'action à ce sujet** et de m'accuser réception de la présente circulaire.

*Signé : S.A. Sisowath Sirik Matak*

# សាលាមធ្យមសិក្សាកសិ



ថ្នាក់រៀនអំពីការហត្ថកម្ម នៅសាលាមធ្យមសិក្សាកសិកម្ម នៅ ខ្ទីវ ហ្វេង,
ក្នុងសង្កាត់ គិនហ្វា, ខែត្រពេខ្វាង

# ភឃ្ស នៅប្រទេសចិន

ដោយ ដេន ក្វាង - វ៉ើង

ប្រែដោយ ទីវ អុល

**នៅ** ប្រទេសចិនថ្មី សាលាមធ្យមសិក្សាកសិកម្ម ជាអគារសិក្សាបែបថ្មីម្យ៉ាង ដែលភ្ជាប់ ការអប់រំទៅនឹងការងារបង្កើតផល ។

លក្ខណៈពិសេសរបស់សាលានេះ ឋិតនៅក្នុងកាលវិភាគ emploi du temps ដែលបែងចែកការសិក្សានៅសាលាហើយនិងការងារនៅស្រែចំការ ។

« ការរំដោះ » បានធ្វើឲ្យកសិករក្រ ហើយនិងកសិករមធ្យមភាគច្រើនដែលស្រទាប់ក្រោម បានឃើញឋានៈនយោបាយរបស់ខ្លួនផ្លាស់ប្ដូរជាប្រាកដ ហើយឋានៈសេដ្ឋកិច្ចរបស់ខ្លួនកាន់តែប្រសើរឡើងៗ ជារៀងរាល់ថ្ងៃពិតមែនហើយ ក៏ប៉ុន្តែជាទូទៅ កសិករទាំងនេះ នៅមានភាពយឺតយ៉ាវនៅឡើយ ក្នុងវិស័យចំណេះវិជ្ជា ។ ដូចនេះ ដើម្បីនឹងប្រើប្រាស់ « អំណាចនៃផ្តាច់ការប្រជាធិបតេយ្យប្រជាមានិត » ឲ្យបានពិតប្រាកដ កសិករទាំងនេះ គេាងតែអប់រំប្រាជ្ញារបស់ខ្លួនជាដាច់ខាត ។

ម្យ៉ាងទៀត ដោយហេតុថា សេដ្ឋកិច្ចសហគមន៍មានការរីកចំរើនជាខ្លាំង ដោយហេតុថា យន្តូបនីយកម្មនៃកសិកម្មកាន់តែមានការលូតលាស់ខ្លាំងឡើងៗ ហើយបច្ចេកទេសថ្មីក្នុងការបង្កើតផលកសិកម្មក៏កាន់តែបានផ្សាយជាទូទៅហើយដូចនេះ « ប្រជាសហគមន៍ » ត្រូវការជាបន្ទាន់ នូវអ្នកអភិបាលហើយនិងអ្នកបច្ចេកទេស ។ អ្នកអភិបាល និងអ្នកបច្ចេកទេសនេះ គឺមិនមែនគ្រាន់តែជាអ្នកផ្គត់ផ្គង់ économe ហេរញ្ញិក trésorier

គណៈនី comptable ដែលមានសមត្ថកិច្ច ក្នុងការផ្គត់ផ្គង់ហិរញ្ញវត្ថុដោយខ្លួនឯង autofinancement តែប៉ុណ្ណោះទេ ។ លើសពីនេះទៅទៀត ប្រជាសហគមន៍ក៏នៅត្រូវការជាបន្ទាន់ នូវអ្នកចេះដឹងជ្រៅជ្រះខាងការសិក្សានឹងខាងសុខភាព ( ពេទ្យ ) ព្រមទាំងអ្នកធ្វើការវិទ្យាសាស្ត្រនៅតាមជនបទ les travailleurs sc. ruraux អ្នកឯកទេសខាងឧតុវិទ្យា les spécialistes de la météorologie ខាងជលវិទ្យា hydraulique ខាងវិជ្ជាអំពីដីមានដីជាតិ agrologie ខាងបសុពេទ្យវិទ្យា médecine vétérinaire នឹងខាងកសិកម្មវិទ្យា agronomie ទៀតផង ។ ហេតុនេះហើយ បានជាត្រូវបង្កើតនូវសាលាមធ្យមសិក្សាកសិកម្ម ជាការចាំបាច់ប្រញាប់ណាស់ ហើយផ្សាយជាទូទៅនូវ " របៀបអប់រំតាមការកសិកម្មពាក់-កណ្ដាល ការសិក្សាពាក់កណ្ដាល " le système d'éducation mi-travail agricole mi-étude ឲ្យមានល្បឿនទៅជាមួយគ្នា នឹងការខិតខំជំរុញល្បឿននៃសាលាបឋមសិក្សារៀនពេញលេញ នឹងសាលាមធ្យមសិក្សារៀនពេញពេល à plein temps ។

នៅក្នុងសាលាមធ្យមសិក្សាកសិកម្ម សាស្ត្រាចារ្យបង្រៀនផង ធ្វើការងារនៅស្រែចំការផង ។ ដូចនេះ គឺភ្ជាប់ការបង្រៀននឹងការប្រតិបត្តិ ។ ចំណែកឯសិស្សវិញ ចំណាយពេលទៅលើការសិក្សាផង ទៅលើការងារបង្កើតផលផង ឯសិក្សានេះទៀត គឺសិក្សាត្រឹមតែចំណេះណាដែលគេត្រូវចេះ ហើយដែលគេអាចនឹងយកទៅអនុវត្តបានតែប៉ុណ្ណោះ ។

សាលាមធ្យមសិក្សាកសិកម្មនេះ ប្លែកគ្នាពីអគារសិក្សារៀនពេញពេលដែលរដ្ឋបង្កើតឡើង ហើយប្លែកគ្នាពី " ថ្នាក់រៀនពេលយប់ " cours de soir ដែលប្រព្រឹត្តទៅនៅក្នុងរោងចក្រ ក្នុងសហគ្រាស ឬក្នុងក្រសួងនានានៃរដ្ឋាភិបាល ។ សាលាបែបថ្មីនេះត្រូវ

បានបង្កបង្កើតឡើង ដោយសារប្រជាសហគមន៍ ហើយដើម្បីប្រជាសហគមន៍ ប្រយោជន៍ឲ្យសហគមន៍នេះអប់រំអ្នកកាន់ការរបស់ខ្លួន ដែលចេះដឹងជ្រៅជ្រះ មានសម្បជញ្ញៈសង្គមនិយមហើយមានចំណេះបច្ចេកទេស ព្រមទាំងអប់រំអ្នកបច្ចេកទេស ដែលមានសមត្ថភាពមធ្យម ឬ ថ្នាក់ទាបដោយខ្លួនឯង ។

សាលាមធ្យមសិក្សាកសិកម្មឈរលើគោលការណ៍ « ពឹងផ្អែកលើកម្លាំងខ្លួន ហើយចាត់ចែងការដោយឈ្លាសវៃនិងសន្សំសំចៃ ដោយរក្សាទុកនូវរបៀបធ្វើការដែលប្រកាន់យកនូវការអំណត់ព្យាយាមក្នុងការប្រយុទ្ធនិងការលំបាកទៀតផង ។ សាលានេះខំយកចិត្តទុកដាក់បន្ថយចំណាយរបស់រដ្ឋនិងរបស់សហគមន៍ផង ហើយសំរាលបន្ទុករបស់មាតាបិតាសិស្សផង ។ បើគ្មានអគារនិងតុទេ គ្រូនិងសិស្សនាំគ្នាស្ថាបនានិងធ្វើវត្ថុនោះ ។ ទោះបីគ្រឿងបរិក្ខារមិនសូវល្អទំនើបក្តី ក៏គ្រូនិងសិស្សជាប់ចិត្តជាប់ថ្លើមទៅនឹងសាលារបស់គេខ្លាំងណាស់ ព្រោះនេះជាការដែលគេបានធ្វើនឹងដៃរបស់គេ ។ គេច្រៀងសរសើរសាលាគេថា :

អ្នកធ្វើពីដៃ : តុ ជើងម៉ា និងអគារ

អ្នកចីដៃ : បុគ្គលិក សាលា និងព្រឹត្តិការណ៍ ។

ការអប់រំបែបនេះ បាននាំឲ្យសិស្សមានការចេះដឹងខាងវប្បធម៌និងខាងវិទ្យាសាស្ត្រ ហើយនិងខាងបច្ចេកទេសបង្កើតផល មិនត្រឹមតែក្នុងការសិក្សាប៉ុណ្ណោះទេ ប៉ុន្តែចេះដឹងដោយសារការងារបង្កើតផលទៀតផង ។ លើសពីនេះទៅទៀត អាស្រ័យប្រាក់កាសដែលគ្រូនិងសិស្សយកបានមកពីក្នុងការប្រតិបត្តិរបស់ខ្លួន នោះចំណាយក្នុងសាលាមួយផ្នែកបានរ៉ាប់រងរួច រីឯចំណាយរបស់សិស្សក្នុងការសិក្សានិងក្នុងការរស់នៅប្រចាំថ្ងៃ ក៏បានរ៉ាប់រងរួចដែរ ។ ចំណាយរបស់មាតាបិតាក៏ត្រូវបានសំរាលដែរ ។ ដូចនេះ កូន

កសិករក្រនឹងកូនកសិករមធ្យមនៃស្រទាប់ក្រោម កាន់តែអាចនឹងចូលទៅមធ្យមសិក្សាបានច្រើនឡើង ៗ ។



សិស្សខាងអគ្គិសនី កំពុងពិនិត្យ "ឌីណាមូ l'isolement d'une dynamo ក្រោមការណែនាំរបស់សាស្ត្រាចារ្យ (ទីពីរខាងស្តាំ) នៅសាលាមធ្យមសិក្សាកសិកម្ម ស្យាងលូ, ក្នុងសង្កាត់ លិនតី, ខេត្រ ចាន់ស៊ី ។

## តើធ្វើយ៉ាងណាទៅ ទើបសាលានេះដើរបានស្រួល ?

១. ការបែងចែកការសិក្សានិងការងារបង្កើតផល ត្រូវតែធ្វើឡើងដោយមិនកំណត់តឹងរឹង ទូលំទូលាយ ហើយមានរូបភាពប្លែក ៗ ទៅតាមលក្ខណៈតំបន់នីមួយៗ ៗ ចំពោះសាលាដែលកងផលិតបង្កើតឡើង សិស្សអាចសិក្សានិងធ្វើការងារនៅក្នុងកង ហើយត្រឡប់ទៅទទួលទានបាយនិងទទួលទានដំណេកនៅផ្ទះវិញ ។ ចំពោះសាលាដែលប្រជាសហគមន៍បង្កើតវិញ មានមួយចំណែកអាចនឹងទទួលសិស្សឲ្យស្នាក់អាស្រ័យផង ៗ ចំណែកឯសាលាឯទៀត ៗ ទទួលសិស្សឲ្យនៅស្នាក់អាស្រ័យហើយធ្វើការសព្វសារពើនៅក្នុងសាលាតែម្តង ។

២. កាលវិភាគខាងការសិក្សានិងខាងការបង្កើតផល ត្រូវលៃយ៉ាងណាឲ្យសិស្សបានរៀនតិច ឬច្រើនជាងធ្វើការ ទៅតាមតែសេចក្តីត្រូវការក្នុងរដូវនីមួយៗ ៗ ក្នុងរដូវ

ការងារពេញទំហឹង សិស្សវិលទៅសាលាសោះតែម្តង ។ ប៉ុន្តែកាលវិភាគបានកែលក យ៉ាងណាទៅតាមគោលការណ៍ដែលតំរូវឲ្យ ឲ្យតម្លៃទៅការសិក្សានិងការបង្កើតផលស្មើគ្នា ។ ដូចនេះ ទូទាត់ទៅ គេបានសិក្សាប្រហែលជាប្រាំមួយខែ ហើយធ្វើការហត្ថកម្មប្រហែលជាប្រាំខែ ។ វិស្សមកាលប្រហែលជាមួយខែ ។

៣. កម្មវិធីនិងមុខវិជ្ជាសិក្សា ត្រូវជ្រើសរើសទៅតាមគោលការណ៍ « តិច ប៉ុន្តែប្រសើរ » និងគោលការណ៍ « ទ្រឹស្តីត្រូវជាប់នឹងការប្រតិបត្តិ » ។ ការនេះមានបំណងនឹងធ្វើឲ្យសិស្សបានជ្រួតជ្រាបច្បាស់ហើយបានអនុវត្តវិជ្ជាដែលខ្លួនបានសិក្សារួចមកហើយ ។ បើនិយាយជាទូទៅ មុខវិជ្ជាទាំងអស់មានបួនគឺ :

— នយោបាយ

— ភាសាចិន

— គណិតវិទ្យា

— ហើយនិងកសិកម្មវិទ្យា ។

ចំពោះខ្លឹមសារនៃការសិក្សាវិញ គេបានយកចិត្តទុកដាក់ជាពិសេសទៅលើវិជ្ជាណាដែលជាប់ទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការបង្កើតផលហើយនិងជីវភាពនៅជនបទ ដូចជាវិជ្ជាខាងឆ្លើយឆ្លងគ្នា correspondance វិជ្ជាគិតតាមក្បាច់ គណនេយ្យ ស្ថិតិ ការសរសេរតាមដក់ ហើយនិងវិជ្ជាជាមូលដ្ឋានឯទៀតៗ ដែលទាក់ទងនឹងការបង្កើតផល ។

ក្នុងការសិក្សា គេបានសំរេចយកវិធី « យកបីមកបង្រួមជាមួយ » បានសេចក្តីថា

— បញ្ចូលការសិក្សាទៅក្នុងការងារបង្កើតផល និងក្នុងការពិសោធន៍វិទ្យាសាស្ត្រ;

— គួបផ្សំការខិតខំរបស់សាស្ត្រាចារ្យ របស់សិស្សនឹងរបស់កសិករមានវ័យចាស់ជាមួយគ្នា;

— គួបផ្សំការខិតខំរបស់សាលា របស់កងផលិត brigade de production នឹងរបស់ "ស្ថានីយជនបទទាំងបួន" ជាមួយគ្នា ។

ឯស្ថានីយជនបទទាំងបួននេះ គឺ :

— ស្ថានីយ "ត្រាក់ទ័រ" station de tracteurs

— ស្ថានីយ ម៉ាស៊ីនបូមទឹក

— ស្ថានីយផ្សាយបច្ចេកទេសឲ្យប្រតិបត្តិទូទៅ

— នឹងស្ថានីយវិជ្ជាបសុពេទ្យ

វិធីសិក្សាដែលគួបផ្សំទ្រឹស្តីទៅនឹងការប្រតិបត្តិបែបនេះ នាំឲ្យសិស្សជ្រួតជ្រាប ហើយក្តាប់បាននូវវិជ្ជាជាមូលដ្ឋានពីរយ៉ាង គឺ :

— ចំណេះវិជ្ជាជាមធ្យម

— នឹងសមត្ថភាព ហើយនឹងសម្បទាក្នុងផ្នែកកសិកម្ម ។

ដោយហេតុតែសិស្សក្ខុសិស្សសិក្សាបណ្តើរ ធ្វើការនៅក្នុងស្រែចំការបណ្តើរបែបនេះ ម្យ៉ាងគេអាចនឹងជ្រួតជ្រាបកាន់តែជ្រៅជ្រះឡើងទៀត នូវការសិក្សារបស់ខ្លួន ដោយខិតខំសាកល្បងដោះស្រាយនូវបញ្ហាទាំងឡាយ ដែលការងារបង្កើតផលបានចោទឡើង ហើយម្យ៉ាងទៀត គេអាចនឹងយកចំណេះដែលគេបានរៀនរួចហើយ មកអនុវត្តក្នុងការងារបង្កើតផល ។

ចំពោះសាស្ត្រាចារ្យវិញ ការអនុវត្តនូវរបៀបសិក្សាដែលគួបផ្សំជាមួយនឹងការប្រតិបត្តិបែបនេះ មិនមែនគ្រាន់តែនាំឲ្យគេបានពិចារណា - យល់ជ្រៅជ្រះនូវមុខវិជ្ជាទាំងប៉ុន្មានក្នុងកម្មវិធី ក្នុងការងារបង្កើតផលតែប៉ុណ្ណោះទេ ប៉ុន្តែការងារប្រតិបត្តិបែបនេះ អាចនាំឲ្យគេលំអមេរៀនរបស់គេ កាន់តែបានជ្រៅជ្រះ នឹងពេញលេញថែមទៀតផង ។

សាលាមធ្យមសិក្សាកសិកម្ម ដែលគួបផ្សំយ៉ាងសុខដុមរមនា នូវការសិក្សាជាមួយនឹងការងារនៅក្នុងស្រែចំការបែបនេះ បានធ្វើឲ្យការបង្រៀន នឹងការសិក្សាមានលក្ខណៈកាន់តែប្រសើរឡើង ៗ ពីព្រោះសិស្សសិក្សាអំពីអ្វីដែលខ្លួនត្រូវយកទៅប្រតិបត្តិបាន ។ អនាគតមួយដ៏ស្រស់បំព្រង ពោរពេញទៅដោយជោគជ័យ បានបើកនៅពីមុខស្ថាប័នសិក្សាបែបថ្មីនេះ ។

បណ្ណាគារ អន្តរជាតិ

លេខ 150 G មហាវិថីនេរុ ភ្នំពេញ

មានលក់សៀវភៅជាភាសាខ្មែរ ជាភាសាបារាំង នឹងសៀវភៅទស្សនាវដ្ដីដែលផ្សាយចេញនៅប្រទេសចិន វៀតណាម នឹងនៅសហភាពសូវៀត ។

រង្វាន់ 20 % នឹងមានជូនចំពោះមិត្តណាដែលទៅទិញ ហើយដែលបានបង្ហាញបណ្ណសមាជិក ។

# កិច្ចការសមាគម

## 1 ញត្តិ

ថ្វាយសម្តេចព្រះប្រមុខរដ្ឋ

- ប្រឆាំង បដិសេធការមួលបង្កាច់របស់រដ្ឋការ បាងកក
- នឹងកាសែត " អាត្លង់ទិច " នឹង " តែម "

ដោយបានស្តាប់ព្រះរាជសាសន៍ ដែលព្រះអង្គទ្រង់បានសព្វព្រះរាជហឫទ័យផ្សាយតាមវិទ្យុជាតិកាលពីថ្ងៃ ៣០ មករា ១៩៦៦ ចំពោះប្រជាជាតិ

ដោយបានដឹងតាមព្រះរាជសាសន៍នេះថា រាជការបាងកកទើបតែនឹងបានប្តឹងអង្គការសហប្រជាជាតិអំពីនយោបាយដែលគេចោទថា " នយោបាយអត្តឃាតកម្ម " របស់សម្តេច។

ហើយដោយបានដំណឹងតាមព្រះរាជសាសន៍ដដែលនេះទៀតថា បន្ទាប់មកមានទស្សនាវដ្តីអាមេរិកាំងឈ្មោះ " អាត្លង់ទិច " នឹង " តែម " ដែលបក្រពត្រអាមេរិកវិញដាច់ថ្ងៃទៅហើយ បានយកការចោទប្រកាន់ដ៏អយុត្តិធម៌របស់ខ្ញុំកញ្ជះរាមកចុះផ្សាយបន្តទៅទៀត ដោយថែមទាំងបញ្ជាក់ថា សព្វថ្ងៃនេះ ពលរដ្ឋ ព្រះសង្ឃ ទាហាន គ្រូបង្រៀន នឹងយុវជនខ្មែរកំពុងតែមិនសប្បាយចិត្តនឹងព្រះអង្គ ហើយនឹងព្រះរាជនយោបាយព្រះអង្គ

ទូលព្រះបង្គំទាំងឡាយ ជាសមាជិកគណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យខ្មែរ

មានសេចក្តីក្តៅក្រហាយយ៉ាងខ្លាំងក្លា នឹងល្បិចកលដ៏ឧក្រិដ្ឋរបស់ចក្រពត្រអាមេរិកកាំងនឹងអាយ៉ងបាងកកដែលបានរួមគ្នាប្រឌិតនូវលេសចោទប្រកាន់ដ៏លាមកថ្មីនេះ ។

ចក្រពត្រអាមេរិកកាំងនឹងបរិវារប្រឌិតរហស្យបាយនេះឡើង ក្នុងគោលបំណងដ៏ខ្មៅងងឹតនឹងចូលរុករានប្រទេសខ្មែរ ដោយគេចផុតពីការផ្ដន្ទាទោសនៃមតិអន្តរជាតិ ។

ប៉ុន្តែប្រជារាស្ត្រខ្មែរក៏ដូចជាប្រជារាស្ត្រសាកលលោក សុទ្ធតែបានស្គាល់ស្នៀតដ៏ឧក្រិដ្ឋរបស់ចក្រពត្រអាមេរិកកាំង នឹងខ្ញុំកញ្ជះវានេះដល់ហួសគល់អស់ហើយ គឺថាពួកវាប្រឌិតលេសថ្មីនេះឡើង បន្ទាប់ពីពួកវាបាទផ្ដត់ផ្គង់រដ្ឋប្រហារដាបឈួន បន្ទាប់ពីបានរៀបចំផែនការក្បត់របស់អាសមសារី នឹងអាសុងសាក់ហើយបន្ទាប់ពីពួកវាចូលឈ្លានពានព្រំដែនខ្មែរពុំបានសំរេចផលមក ។

ហេតុនេះ ទូលព្រះបង្គំទាំងឡាយ សូមបដិសេធយ៉ាងដាច់អហំការ នូវការមួលបង្កាច់ខាងលើនេះ ពីព្រោះព្រះរាជនយោបាយសម្តេចឪ គឺពិតជានយោបាយស្រោចស្រង់ប្រជាជាតិ ដែលបានទទួលនូវការគាំទ្រពីប្រជាជាតិជាឯកច្ឆន្ទ ។

ហើយសូមប្រកាសយ៉ាងឧឡារិកថា សាស្ត្រាចារ្យពល់រូបសុទ្ធតែរក្សាសេចក្តីស្វាមីភក្តិឥតរង្គោះរង្គើរបស់ខ្លួនចំពោះសម្តេចឪ ចំពោះព្រះរាជនយោបាយឯករាជ្យ នឹងបង្រួបបង្រួមជាតិរបស់ព្រះអង្គឥតមានរវាតពេលណាឡើយ ។

ក្នុងឱកាសនេះ ទូលព្រះបង្គំទាំងឡាយ សូមប្តេជ្ញាសាជាថ្មីទៀត នឹងដង្ហែសម្តេចឪនៅលើមាគ៌ាដ៏រុងរឿងនៃសាមគ្គីភាពជាតិ ប្រឆាំងនឹងចក្រពត្រអាមេរិកកាំង ប្រឆាំងនឹងអាយ៉ងព្រៃនគរនឹងបាងកក ប្រឆាំងនឹងអាយ៉ង «ខ្មែរសេរី» ដែលមានអាថាន់ អាសារី អាសុងសាក់ជាមេ ហើយប្រឆាំងនឹងដៃជើងរបស់វាទាំងជិត ទាំងឆ្ងាយ លុះដល់ជោគជ័យជាអវសាន្ត ។

សេចក្តីគួរពុំគួរសូមទ្រង់ព្រះមេត្តាប្រោស

ភ្នំពេញ នៅថ្ងៃ៥ កុម្ភៈ ១៩៦៦

បន្ទាប់ពីបានថ្វាយញត្តិនេះមក សម្តេចឪទ្រង់បានត្រាស់បញ្ជាឲ្យ សហជីវិន ចៅ សេង ឆ្លើយតបមកយើងវិញ នូវសេចក្តីដូចខាងក្រោមនេះ :

ខុទ្ទកាល័យនៃសម្តេចសហជីវិន
ព្រះប្រមុខរដ្ឋ
CABINET DE SAMDECH SAHACHIVIN
CHEF DE L'ETAT

N° 476. S. P. U./ II

ព្រះរាជអាណាចក្រកម្ពុជា

Phnom - Penh, le 12 Février 1966

Le Directeur de Cabinet du Chef de l'Etat

à Sahachivin Meas Dim Président du Comité Directeur de l'Association des Professeurs Khmers.
PHNOM - PENH

Objet : Réponse aux journaux « Times » et « Atlantic ».

Référence : Votre motion en date du 4 - 2 - 66.

Comme suite à votre motion citée en référence, j'ai l'honneur de vous informer que Samdech Sahachivin a daigné annoter comme suit :

« Sahachivin Chau Séng. Nos compatriotes intéressés pourraient écrire directement à ces journaux ennemis. Cela aurait plus d'effet. »

Samdech a paraphé

Je vous prie en conséquence de bien vouloir donner suite aux Très Hautes Instructions princières.

Ci-joint : une photocopie des annotations.

CHAU SENG

# ចក្រពត្តិអាមេរិកាំង...




Le faucon paré des plumes de la colombe

Caricature de Jack Chen

ដកស្រង់ពី : Pékin Information— 17 - I - 66

# ...និងបរិវារ

*Le Musée des Horreurs*




ដកស្រង់ពី : Kambuja — 15 - I - 66

# ចម្លើយនៃ ស·ស·ខ

ចំពោះ

2

- អ្នកដឹកនាំ បាងកក ហើយនឹង
- កាសែត " អាត្លង់ទិច " នឹង " តែម "

នែ អ្នកដឹកនាំ ថៃ !

នែ កាសែត " អាត្លង់ទិច " នឹង " តែម " !

ក្នុងពេលថ្មី ៗ នេះ ពួកឯងបាននាំគ្នាប្រគុំភ្លេងវង់ធំមួយ ប្រឆាំងនឹងខ្មែរ ។ ឯងបានចោទសម្តេចឪជាទីគោរពរបស់ខ្មែរថា ព្រះអង្គទ្រង់កំពុងអនុវត្តនូវ " នយោបាយអត្តឃាតកម្ម " ថាយុវជន ព្រះសង្ឃ គ្រូបង្រៀន កំពុងក្តៅក្រហាយ នឹងព្រះអង្គ ។ ល ។

រាស្ត្រខ្មែរនឹងសាកលលោក គេបានស្គាល់មុខមាត់ដ៏កខ្វក់របស់ចៅហ្វាយអាមេរិកាំង នឹងរបស់ពួកឯងជាអាយ៉ងយ៉ាងច្បាស់ណាស់ទៅហើយ ។ យ៉ាងណាមិញ រឿងរដ្ឋប្រហារមិនសំរេចរបស់ដាបឈួន រឿងគ្រាប់បែកផ្ទាស្ងួចក្នុងវាំង រឿងសមសារី រឿងសុងសាក់ រឿងគ្រាប់បែកកប់តាមផ្លូវពោធិចិនតុង រឿងប៉ុនប៉ងធ្វើឃាតព្រះប្រមុខរដ្ឋនៅមេមត់ រឿងឈ្លានពានព្រំដែនជាហូរហែមិនដាច់ រឿងទាំងនេះតើពុំមែនជាផលិតផល ដ៏ឧក្រិដ្ឋរបស់ចៅហ្វាយឯងនឹងពួកឯងឬ ?

ឥឡូវនេះ ពួកឯងខំស្រែកចោទមួលបង្កាច់ខ្មែរម្តងទៀត ក្នុងបំណងរៀបចំសាធារណមតិ ឲ្យជួយឧបត្ថម្ភចៅហ្វាយឯង ដើម្បីចូលមកលុកលុយពាតព្បាតស្រុកខ្មែរបានដោយគ្មានទោសទៀត ។ ឯងយល់ច្រឡំធំហើយ ! លេសដែលឯងខំបង្កើតថ្មី ៗ នេះ ពិតជា

ពុំអាចនាំឯងទៅដល់គោលបំណងដ៏ខ្មៅងងឹតនោះបានជាដាច់ខាត ។ អំពើតិរច្ឆាន សំដីផ្តេសផ្តាសរបស់ពួកឯងរឹតតែធ្វើឲ្យពលរដ្ឋខ្មែរ ខ្ពើមឆ្អើមចៅហ្វាយឯងខ្លាំងឡើង ៗ ហើយក៏រឹតតែធ្វើឲ្យពលរដ្ឋខ្មែរទាំងអស់ស្រឡាញ់គ្នា និងគោរពសម្តេចឪ និងព្រះរាជនយោបាយឯករាជ្យ សន្តិភាព អព្យាក្រឹត បង្រួបបង្រួមជាតិ វឌ្ឍនភាព របស់ព្រះអង្គខ្លាំងឡើងៗដែរ ។

ក្នុងចំណោមពលរដ្ឋខ្មែរទាំងអស់ យើងសាស្ត្រាចារ្យសូមប្រកាសប្រាប់ឯងជាឧឡារិកថា ភក្តីភាពរបស់យើងចំពោះសម្តេចឪ ចំពោះនយោបាយរបស់ព្រះអង្គមានសភាពរឹងប៉ឹងគ្មានអ្វីអាចនឹងមកធ្វើឲ្យរង្គោះរង្គើបន្តិចឡើយ ទោះបីការមួលបង្កាច់របស់ឯងក្តី របស់ចៅហ្វាយឯងក្តី របស់ឯងនិងចៅហ្វាយឯងរួមគ្នាក្តី ។

ចំពោះយើង ក៏ដូចជាចំពោះពលរដ្ឋខ្មែរទូទៅ នយោបាយរបស់សម្តេចឪ គឺជានយោបាយស្រោចស្រង់ជាតិ សាមគ្គីជាតិ នយោបាយដ៏ថ្លៃថ្នូររបស់ជាតិ ។

បើប្រសិនជាមានខ្មែរខ្លះពុំសប្បាយចិត្តនឹងនយោបាយនេះ ខ្មែរនោះ គឺពួកអា « ខ្មែរសេរី » អាថាន់ អាសារី អាសុងសាក់ និងពួកដៃជើងរបស់វាមួយក្តាប់តូច ដែលសុទ្ធសឹងតែជាបរិវារកញ្ជះបាតជើងរបស់អាមេរិកាំង ដូចជាពួកឯងដែរនោះ គឺអ្នកដឹកនាំថៃ អ្នកនិពន្ធធុនថោកនៃ « ក្រដាសកខ្វក់ » អាតួង់ទិប និង តែម នេះដែរតែប៉ុណ្ណោះ ។

ចូរឯងបើកភ្នែកមើល ហើយល្មមឈប់យកកំហឹង គួរឲ្យអស់សំណើចរបស់ពួកឯងនេះ ថាជាកំហឹងរបស់ពលរដ្ឋខ្មែរ ព្រះសង្ឃ យុវជន និងគ្រូបង្រៀនខ្មែរទៀតទៅ !

ជយោ ព្រះរាជនយោបាយបង្រួបបង្រួមជាតិ !

បរាជ័យ អាមេរិកាំង និងបរិវារទាំងជិតទាំងឆ្ងាយ !

## ការប្រឡងចូល

# សាលាគរុវិជ្ជាជាន់ខ្ពស់

3

តាមសេចក្ដីសម្រេចចិត្តរបស់មហាសន្និបាតប្រចាំឆ្នាំ គ.នាយកនៃ ស. ស. ខ. យើងបានផ្ញើលិខិតមួយ ស្ដីពីការអនុញ្ញាតឲយសាស្ត្រាចារ្យបឋមភូមិដែលបានធ្វើការ ៣ ឆ្នាំហើយ អាចប្រឡងចូលសាលាគរុវិជ្ជាជាន់ខ្ពស់ ទៅជូនលោកសាកលវិទ្យាធិការនៃរាជសាកលវិទ្យាល័យ ភ្នំពេញ ។

នៅថ្ងៃ ២៧ មករា ១៩៦៦ លោកសាកលវិទ្យាធិការក៏បានឆ្លើយតបមកយើងវិញ ។

លុះមកដល់ថ្ងៃ ២៧ កុម្ភៈ យើងបានទទួលសេចក្ដីបញ្ជាក់មួយច្បាប់ទៀត នៃអ្នកអង្គម្ចាស់ទេសរដ្ឋមន្ត្រី ។

ខាងក្រោម គឺជាសេចក្ដីនៃលិខិតទាំងបីនេះ :

### • ១. លិខិតរបស់គ.នាយក ស. ស. ខ

ភ្នំពេញថ្ងៃ ២០ មករា ១៩៦៦

*គណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យខ្មែរ*

*សូមជំរាបមកលោកសាកលវិទ្យាធិការ នៃរាជសាកលវិទ្យាល័យភ្នំពេញ*

*តាមរយៈលោកព្រឹទ្ធសាស្ត្រាចារ្យនៃមហាវិទ្យាល័យគរុកោសល្យ*

**កម្មវត្ថុ:** *ការសូមអនុញ្ញាតឲយសាស្ត្រាចារ្យបឋមភូមិដែលធ្វើការបាន៣ ឆ្នាំអាចប្រឡងចូលសាលាគរុវិជ្ជាជាន់ខ្ពស់*

*យើងខ្ញុំជាសមាជិកនៃគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ*

*ដោយអនុលោមទៅតាមគំនិតនៃលក្ខន្តិកៈសមាគម ដែលមានគោលបំណងនឹងការពារផលប្រយោជន៍សមាជិកផង*

ហើយដោយអនុលោមទៅតាមសេចក្ដីសំរេចចិត្តជាឯកច្ឆន្ទរបស់ មហា-សន្និបាតបុនក្រោយបង្អស់ ថ្ងៃ ២៣ – ៨ – ៦៥ របស់សមាគមផង

សូមលោកសាកលវិទ្យាធិការមេត្តាពិនិត្យឡើងវិញ ដោយអនុគ្រោះនូវយថាហេតុនៃការអនុញ្ញាតឲ្យសាស្ត្រាចារ្យបឋមភូមិ ដែលធ្វើការបាន ៣ ឆ្នាំយ៉ាងតិចរួចមកហើយ មានសិទ្ធិបានប្រឡងចូលសាលាគរុវិជ្ជាជាន់ខ្ពស់ជាមួយនឹងសាស្ត្រាចារ្យ ដែលមានវិញ្ញាបនប័ត្រ « Propédeutique » ផង ។ ការសំរេចបែបនេះ នឹងធ្វើឲ្យសាស្ត្រាចារ្យ ដែលគ្មានភ័ព្វនឹងបានធ្វើការនៅភ្នំពេញនឹងគេ បានឡើងទឹកចិត្តហើយឧស្សាហ៍បន្តកិច្ចសិក្សារបស់ខ្លួនតទៅទៀត ព្រោះមានសង្ឃឹមក្នុងចិត្តជានិច្ច ជាហេតុដែលធ្វើឲ្យកិច្ចការបង្រៀនសិស្សរបស់ខ្លួនក៏បានលទ្ធផលល្អប្រសើរថែមទៀតផង ។

សូមលោកទទួលនូវសេចក្ដីគោរពជាទីបំផុតអំពីយើងខ្ញុំ ។

មាស ឌឹម

* * *

**ខេមរបណ្ណាគារ**

លេខ 174 វិថីខេមរភូមិន្ទ ភ្នំពេញ

មានសេចក្ដីរីករាយនឹងបុះថ្លៃ 15 % ជូនមិត្តយើងណាដែល

ទៅទិញសៀវភៅខ្មែរ នៅបណ្ណាគារនេះ ។

សូមបង្ហាញបណ្ណសមាជិក !

## ២. សេចក្ដីឆ្លើយតបនៃលោកសាកលវិទ្យាធិការ

សាកលវិទ្យាធិការ នៃ សាកលវិទ្យាល័យភូមិន្ទ

សូមជំរាបមក

សហជីវិនប្រធានគណៈកម្មាធិការនាយក នៃសមាគមសាស្ត្រាចារ្យខ្មែរ

ភ្នំពេញ ។

តាមរយៈសហជីវិនព្រឹទ្ធសាស្ត្រាចារ្យ នៃមហាវិទ្យាល័យគរុកោសល្យ

កម្មវត្ថុ : ការសូមអនុញ្ញាតឲ្យសាស្ត្រាចារ្យបឋមភូមិ ដែលធ្វើការបាន ៣ ឆ្នាំ អាចប្រឡងចូលសាលាគរុវិជ្ជាជាន់ខ្ពស់

យោង : លិខិតរបស់សហជីវិន លេខ ១៥៥-គន-១០ ចុះថ្ងៃទី ២០-១-៦៦

តបនឹងលិខិតខាងលើនេះ ខ្ញុំសូមជំរាបសហជីវិនថា ខ្ញុំឥតមានយល់ទាស់នឹងសំណូមពរដែលសហជីវិនបានផ្ញើទៅឲ្យខ្ញុំនោះទេ គឺខ្លួនខ្ញុំក៏មានយោបល់ខ្លះដូចជាយោបល់របស់សហជីវិនដែរ ប៉ុន្តែសូមសហជីវិនជ្រាបថា ចំពោះការបង្កើតសាលាគរុវិជ្ជាជាន់ខ្ពស់នេះ រាជរដ្ឋាភិបាលយើងបានធ្វើសេចក្ដីព្រមព្រៀងមួយជាមួយនឹងប្រទេសបារាំងថា នឹងរើសឲ្យចូលអប់រំខាងផ្នែកសាស្ត្រាចារ្យមធ្យមភូមិតែបេក្ខជនណា ដែលមានបុព្វសិក្ខាប័ត្រ « Propédeutique » ។

បើទុកជាយ៉ាងដូច្នេះក៏ដោយ ក៏ខ្ញុំផ្ញើរឿងនេះថ្វាយអ្នកអគ្គមហាសេនាបតីទេសរដ្ឋមន្ត្រី ដើម្បីសូមសេចក្ដីសម្រេចរបស់ទ្រង់ ។

សូមសហជីវិនរង់ចាំ សេចក្ដីសម្រេចនោះចុះ ។

ភុង តុន

## • ៣. សេចក្តីបញ្ជាក់នៃអ្នកអង្គម្ចាស់ទេសរដ្ឋមន្ត្រី

Phnom-Penh, le 17 Février 1966

LE MINISTRE D'ETAT, CHARGE DE L'EDUCATION NATIONALE
A Sahachivin Recteur de l' Université Royale

à PHNOM-PENH

OBJET : Autorisation de se présenter au concours d'entrée à l'Ecole Normale Supérieure sollicitée par le Comité Directeur de l'Association des Professeurs Khmers.
REFERENCE : Votre lettre n°-365 RUR du 31 Janvier 1966

Faisant suite à votre lettre sus référée, j'ai l'honneur de vous faire connaître que l'accord signé avec la France concernant l'Ecole Normale Supérieure, a été conçu dans l'esprit de faire des Professeurs du 2e Cycle des gens de valeur internationale et tout désignés pour l'enseignement de ce cycle.

En conséquence vous voudrez bien faire comprendre au Comité Directeur de l'Association des Professeurs Khmers que le statut de la future Ecole Normale Supérieure ne sera pas modifié.

*Signature* : Siscwath Sirik Matak

បណ្ណាគារ គីម គី

លេខ 95 វិថីព្រះយុគន្ធរ ភ្នំពេញ

បណ្ណាគារ គីម សេង

លេខ 223 មហាវិថី ព្រះមុនីវង្ស ភ្នំពេញ

មានសេចក្តីរីករាយនឹងចុះថ្លៃ 20 % ជូនសមាជិកនៃ សមាគម សាស្ត្រាចារ្យខ្មែរ ដែលទៅទិញសៀវភៅខ្មែរនៅបណ្ណាគារទាំងនេះ ។

សូមបង្ហាញបណ្ណសមាជិក !

## ការប្រឡងចូល

# មហាវិទ្យាល័យគរុកោសល្យ

យើងបានទទួលដំណឹងថា ចាប់តាំងពីឆ្នាំក្រោយទៅ មហាវិទ្យាល័យគរុកោសល្យ នឹងអនុញ្ញាតឲ្យប្រឡងចូលតែបេក្ខជនណា ដែលមានមធ្យមសិក្សាប័ត្រភាគទី ២ ទោះបីបេក្ខជននោះជាគ្រូបង្រៀនចាស់ក៏ដោយ ហើយគ្រូចាស់នេះ ត្រូវលាពីតំណែងគ្រូមកធ្វើជា
4 និស្សិត ទទួលអាហារូបករណ៍ដូចនិស្សិតឯទៀត ៗ ដែរ ។

ក្រោយពីដឹងយ៉ាងច្បាស់ថា ការស្នើសុំឲ្យលោកគ្រូបំពេញវិជ្ជា នឹងលោកគ្រូមានមធ្យមសិក្សាប័ត្រភាគទី ១ បានចូលប្រឡងផង ពុំបានការ គ.នាយកក៏បានផ្ញើលិខិតមួយច្បាប់ទៅជូនលោកសាកលវិទ្យាធិការ ដើម្បីស្នើសុំឲ្យលោកមេត្តាពិនិត្យមើលករណីលោកគ្រូដែលមានមធ្យមសិក្សាប័ត្រភាគទី ២ ។ លិខិតនេះមានសេចក្ដីដូចខាងក្រោម :

ភ្នំពេញថ្ងៃ ២៤ កុម្ភៈ ១៩៦៦

ប្រធានសមាគមសាស្ត្រាចារ្យខ្មែរ

មកលោកសាកលវិទ្យាធិការនៃរាជសាកលវិទ្យាល័យខ្មែរ

តាមរយៈលោកព្រឹទ្ធសាស្ត្រាចារ្យនៃមហាវិទ្យាល័យគរុកោសល្យ

កម្មវត្ថុ: ករណីនៃគ្រូបង្រៀនដែលប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាភាគទី ២ ប្រឡងចូលមហាវិទ្យាល័យគរុកោសល្យ

ដោយបានដំណឹងថា មានសេចក្ដីសំរេចមួយតំរូវឲ្យគ្រូបង្រៀនដែលបានប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាភាគទី ២ ហើយ ត្រូវប្រឡងចូលមហាវិទ្យាល័យគរុកោសល្យជាមួយនឹងសិស្សឯទៀត ៗ ហើយត្រូវសូមលាឈប់ពីតំណែងទៀតផង ទើបត្រូវអនុញ្ញាតឲ្យចូលទៅរៀនវិជ្ជាអប់រំសាស្ត្រាចារ្យនោះ

គណៈកម្មាធិការនាយកនៃសមាគមសាស្ត្រាចារ្យខ្មែរ បានជំនុំពិភាក្សាគ្នាពីរឿងនេះ

ហើយសូមស្នើដោយគោរពយ៉ាងជ្រាលជ្រៅបំផុតមកលោកសាកលវិទ្យាធិការនៃពជសាកលវិទ្យាល័យខ្មែរ នូវយោបល់នឹងសំណូមពរខ្លះដូចតទៅនេះ

គ្រូបង្រៀនយើងទាំងពីរបានប្រឡងជាប់សញ្ញាប័ត្រមធ្យមសិក្សាភាគទី២ បានខិតខំព្យាយាមខ្លាំងណាស់ ហើយទោះបីដូចនេះក៏ដោយ ក៏ក្នុងមួយឆ្នាំៗ ចំនួនអ្នកជាប់ពុំឡើងហួសពីម្នាក់ ឬពីរនាក់ឡើយ ។ ដោយហេតុថាករណីបែបនេះមានចំនួនតិចផង ដោយហេតុថាពួកនេះត្រូវរៀនតែមួយឆ្នាំផង ហើយដោយហេតុថាគេមានការពិសោធន៍ខាងគរុកោសល្យក៏សមគួរដែរហើយនោះ សមាគមសាស្ត្រាចារ្យខ្មែរសូមស្នើលោកពិនិត្យដោយអនុគ្រោះនូវយថាហេតុខាងក្រោមនេះ គឺ :

១– អនុញ្ញាតឱ្យចូលរៀនដោយពុំបាច់ប្រឡង នូវគ្រូបង្រៀនមានសញ្ញាប័ត្រមធ្យមសិក្សាភាគទី ២ ណាដែលបំពេញរយៈកាលកម្មសិក្សា (stagiaive) នៅឡើយ ព្រមទាំងអនុញ្ញាតឱ្យគេរក្សាតំណែង នឹងទទួលបៀវត្សដដែលផង ដើម្បីចិញ្ចឹមគ្រួសារ ហើយដើម្បីនឹងរៀនបានផង ។

២– តែងតាំងជាសាស្ត្រាចារ្យតែម្តង តែឱ្យបំពេញរយៈកាលកម្មសិក្សាមួយឆ្នាំសិន នូវគ្រូដែលបានចូលក្នុងគ្របខណ្ឌចាប់តាំងពីថ្នាក់ទី ៤ ឡើងទៅ ហើយដែលមានសញ្ញាប័ត្រមធ្យមសិក្សាភាគទី ២ តាមសម្មាមាត្រនៃបៀវត្សនៃក្រិត្យក្រមក្នុងគ្របខណ្ឌផ្លាស់ប្តូរ " គ្រូបំពេញវិជ្ជាទៅជាសាស្ត្រាចារ្យបឋមភូមិ " ។

សូមលោកទទួលនូវសេចក្តីគោរពយ៉ាងជ្រាលជ្រៅបំផុតអំពីយើងខ្ញុំ ។

សមាគមសាស្ត្រាចារ្យខ្មែរ

ប្រធាន : មាស ឌឹម

## • លិខិតឆ្លើយតបចំពោះសំណូមរបស់យើងខាងមុខ

MINISTERE
DE
L'EDUCATION NATIONALE

N° 38 SGCSUR

Phnom Penh, le 19 Mars 1966

LE MINISTRE D'ETAT, CHARGE DE L'EDUCATION NATIONALE.

à Sahachivin Recteur de l'Université Royale
à PHNOM PENH

OBJET : Cas des Instituteurs bacheliers, candidats au concours d'entrée à la Faculté de Pédagogie.
Référence : Votre lettre n°-704 RUR du 2 Mars 1966

En réponse à votre lettre susvisée, j'ai l'honneur de vous faire connaître que je ne peux pas accepter les doléances présentées par le Comité - Directeur de l'Association des Professeurs Khmers, lesquelles ne cadrent pas avec la politique de désengagement du Gouvernement Royal et, en plus, dépassent les dispositions du Kret N°- 365-CE du 27-9-60, modifié et complété par les textes subséquents, portant statut des Professeurs de l'Enseignement Secondaire du 1er Cycle.

En conséquence, je vous prie de bien vouloir en aviser ledit Comité-Directeur.

*Signature :* SISOWATH SIRIK MATAK


បណ្ណាគារ នាគ ឆត្រ សំបូណ៌

លេខ 78 វិថីព្រែនគរ ភ្នំពេញ

នឹងចុះថ្លៃសៀវភៅយ៉ាងគាប់ចិត្តជូនមិត្តយើង ហើយនឹងចុះថ្លៃជាពិសេសថែមទៀត ចំពោះសៀវភៅណាដែលមិត្តយើងមកបញ្ជាទិញ ( នៅប្រទេសបារាំង ) ដោយរួមគ្នាច្រើននាក់ ៗ

សូមបង្ហាញបណ្ណសមាជិក !



# វិទ្យាសាស្ត្រ នឹង សរសេរ កំណាព្យ

## ធំនួ ញឪពុកកំសត់

ដោយ អ៊ុប គ្រឿង

អនុវិទ្យាល័យ ទឹកឃ្លាំង

កូនអើយអាសូរខ្ញុំ ក្រោមកំដៅក្ដៅហែង ១
ជាមួយនឹងម្ដាយឯង ដៃជើងខ្វែងដាំដំណាំ ១
ក្ដៅម៉្លេះទឹងសូរ្យសែង ជះចាំងបែងសែងសូរ្យកាំ
ក្ដៅតីក្ដៅដីដាំ ជើងជាន់ទាំពងបាទខ្ញុំ ១
ក្ដៅផ្ទុបពីលើក្រោម ញើសចេញព្រមជាំជោកក្ដៅ
ញើសស្រោបស្រោបខោអាវ ពណ៌ខ្មៅខ្ញាញ់ខ្មៅទៅជាស ១
កូនអើយអាសូរពុក ពុកកើតទុក្ខ ទុក្ខពុកគត
ទុក្ខទោសព្រោះពុកក្រ ជាដំណាដំណែលមក ១
ផុតពុកខំណាស់ដែរ ពលំថៃខែតែងលែលក
ខំធ្វើខំរះរក ពុកមិនដែលខ្ពិលឡើយណា ១

ទៅស្រែក្រោកពីយប់ ទល់ព្រលប់ជាធម្មតា
សំរាកតែពេលណា ឪពិសានាថ្ងៃត្រង់ ៗ
ព្រលឹមឥតបបរ ពោះចំហកក្រហួង
បើឃ្លានមានបំពង់ ទឹកខាងក្នុងនោះគ្រាន់ស្បើយ ៗ
កូនអើយមើលរូបឪ កក់ស្រមូវពៅពុកអើយ
សក់រីងក្រញឹងហើយ ស្និតសិតសើយស្មើរបាក់បែក ៗ
ខែប្រាំងរាំងសែនក្ដៅ វស្សាកូវក្ដៅមានប្លែក
ត្រជាក់ញាក់ញ័រស្បែក ពេលមេឃស្រែកញែកគ្រាប់ភ្លៀងៗ
តគ្រុន គ្រុន ខ្លាំងណាស់ សមឪចាស់ផ្លាស់រូបរាង
ខ្សោយខ្សត់សព្វាង្គ ក្រោមទឹកភ្លៀងគ្មានជំរក ៗ
កូនអើយភ្លៀងកាចណាស់ មានរន្ទះរះទៅមក
មិនដូចខ្ទះប្រៀងទុក ជាទឹកភ្លៀងប្រៀងបំពោរ ៗ
ភ្លៀងឲ្យទឹកយើងហើយ តែកូនអើយយើងឯងគេ
ដែលតែងតែទៅស្រែ តែរងាជាខូចខុស ៗ
កូនអើយកិច្ចឪរក បានផលមកតិចតួចទាស់
ចាយក្លាមក្លែតសឹងអស់ គួរស្រណោះស្រណោកពេក ៗ
បើកូនយល់ការពុក សុំទ្រលុកពុកកុំត្រេក
ទៅរៀនកុំលេងពេក ត្រូវសង្វេគទឹកភ្នែកពុក ៗ
ត្រង់ត្រាប់ស្ដាប់អាចារ្យ ជាមាគ៌ាដែលដាក់ទុក
បង្រៀនប្រៀនទំនុក ទុកទំនៀមបៀមឲ្យជាប់ ៗ

( តទៅទំព័រទី ៥១ )

# ស្ងាវដៃលោកស្ងួន

( ក្នុងរឿងសូផាត របស់លោក រឹម គិន )

ដោយ ឈូ ណារី

វិទ្យាល័យរាស្ត្រនិយមព្រះសីហនុ

ស្ងួនអើយស្ងួនសក្តិ        ស្ងួនអាងទឹកប្រាក់
ស្ងួនគ្មានមេត្តា        ស្ងួនបោកបញ្ឆោត
ស្រីស្រស់សូយ៉ា        ឲ្យរងវេទនា
កំព្រាទឹងកូន ៗ

សូយ៉ាពុំសុខ        ទៅជាកើតទុក្ខ
របូតសោះសូន្យ        ជីវិតសង្ខារ
ព្រោះខ្លាស់បងប្អូន        ដែលដឹងរឿងខ្លួន
ចាញ់បោកប្រុសប្រាជ្ញ ៗ

នាងទៅជាផេះ        ស្ងួននៅក្រអេះ
ពុំមាននឹកខ្មាស        បានកាន់តែធំ
រឹតមានអំណាច        ចាយប្រាក់បាចហាច
ការប្រពន្ធថ្មី ៗ

តើសមមិនសម        ស្ងួនអាងសក្តិធំ
ដើរបោកស្រី ៗ        សូយ៉ាលង់កាយ
ក្លាយខ្លួនជាដី        ស្ងួនសែនអប្រិយ
បានថ្មីចោលចាស់ ៗ

*

*   *

# អនុវិទ្យាល័យជ័យវរ្ម័នទី ៧

ដោយ សុខ ឡាមីន

បើក្រឡេក ភ្នែកសម្លឹង ប្រឹងគយគន់
ភាពទន់ភ្លន់ នៃអនុ វិទ្យាល័យ
ញញឹមដាក់ មិត្តទាំងអស់ ដោយភក្ដី
ហើយស្រដី សុំអញ្ជើញ ចូលកំសាន្ត ៗ

ព្រោះមានសព្វ គ្រប់កីឡា ការសប្បាយ
បំរើនកាយ មានវាយសី ល្បីចំណាន
ព្រមបាល់ទាត់ បាល់ទះបោះ ស្រស់ក្លូមផាន
សុទ្ធសឹងបាន ជ័យជំនះ គ្រប់វេលា ៗ

រីបុគ្គលិក គ្រប់ ៗ ប្រាណ បានត្រង់ត្រាប់
ចិត្តប្រុងស្ដាប់ ចាប់ឱវាទ ស្អាតថ្លៃថ្លា
លោកចាងហ្វាង តែងរំលឹក ពីកិច្ចការ
ចិត្តសាមគ្គី ជាកម្លាំង ប្រាំងឧបសគ្គ ៗ

មិត្តស្រីប្រុស ស្រុះស្រួលគ្នា ជារាល់ថ្ងៃ
ប្រឹងពួតដៃ លៃកសាង យ៉ាងស្មោះស្ម័គ្រ
ផ្នែកសិក្សា កីឡាផង ចងជំពាក់
មិនទុយអាក់ ស្អាកដំណើរ វឌ្ឍនភាព ៗ

ឯកិច្ចការ កសាងជាតិ មួយចំណែក
គ្មានអល់អែក បុគ្គលិកយើង តែងជ្រួតជ្រាប

ទោះជាប្រាក់ ឫកម៉ាំង គាំងចិត្តរៀប
ទុយមានរបៀប ជាពល់ពេល ឥតអាក់ខាន ៕
សូមជូនពរ បុគ្គលិកយើង ជួបតែសុខ
ចាកផុតទុក្ខ ដែលរុកពត បៀតបៀនប្រាណ
សូមកិច្ចការ ថ្លាត្រចះ ល្អះឥតល្អាន
សូមទុយបាន តែជោគជ័យ ល្បីរន្ទឺ ៕

តមកពីទំព័រ ៤៨

រំទន្ទេញខ្ទង់ បូរកូនក្រែងជាទម្លាប់
គិតគូរយូរទៅគាប់ កុំគិតធាប់កំពុចបុណ្យ ៕
ការកូនៗ គឺរៀន អប់រំប្រាណោមានថែកគុណ
ការខុសគឺរៃកពុន ដាំដកស្ទូងឈាន់រកទ្រព្យ ៕
ទំនុកពុកកំសត់ ទ្រព្យបុត្រទល់ទីគាប់
ទុកកូនសូនចំណាប់ នេះសម្បថបទខុបា ៕

**មិត្តទាំងឡាយ !**

ទស្សនាវដ្ដីសាស្ត្រាចារ្យ រង់ចាំទទួលជានិច្ច នូវអត្ថបទរបស់មិត្ត ៗ បើមានមតិល្អផុសឡើងហើយ សូមមិត្តសរសេរ និង ផ្ញើមកយើងភ្លាម កុំឱ្យមតិនេះរលាយបាត់ទៅវិញឥតប្រយោជន៍ ៗ

សូមអរគុណទុកជាមុន !

# LA REFORME DE L'ORTOGRAF

*par* Gérald Messadie
(*in* Science et Vie - *mai* 1965)

Si l'on vous disait que, vers la fin de ce siècle, décidément riche en surprises, les jeunes français apprenant l'orthographe, ou plus exactement *l'ortograf*, pourront impunément écrire de la façon suivante ce texte tiré de « Thaïs », d'Anatole France :

*« Les anciens du désert étendaient leur puissance sur les pécheurs et les impies. Leur bonté était parfois térible. Ils tenaient des apôtres de punir les ofenses faites au vrai Dieu. et rien ne pouvait sauver ceus qu'ils avaient condanés. L'on contait avec épouvante dans les villes et jusque dans le peuple d'Alexandrie que la tère s'entrouvrait pour engloutir les méchants qu'ils frapaient de leur baton. Aussi étaient-ils très redoutés des méchants de mauvaise vie, et particulièrement des mimes. des baladins, des prêtres mariés et des courtisanes.*

*« Tèle était la vertu de ces religieus qu'èle soumetait à leur pouvoir jusqu'aus bêtes féroces...»*

Qu'en diriez-vous ? Dix erreurs sanctionnées par un dix sur dix ? Vous demanderez alors spirituellement si ce genre de dictées sera proposé par des professeurs du Lycée Papillon, des disciples de Raymond Queneau, des professeurs venus de la planète Mars ou des ennemis de la France.

Pas du tout : ce texte sera approuvé par des professeurs chargés d'enseigner la nouvelle orthographe de la langue française, imposée par arrêté ministériel avec l'approbation de l'Académie Française, de l'Institut et de bon nombre de personnalités françaises en possession de toutes leurs facultés intellectuelles.

Et si l'on vous disait que cet arrêté ministériel est déjà prêt dans les tiroirs du ministre de l'Education Nationale ? Vous paliriez sans doute un peu et vous parleriez de « braderie », peut être. Mais si l'on vous apprenait encore que parmi les prétendus bradeurs de notre patrimoine culturel figurent dans le seul domaine des sciences des personnalités telles que les professeurs Gaudart d'Allaines, Combes, feu Esnault - Peleterie, Gramont, Lacassagne, Léauté, Leprince-Ringuet, Francis-Perrin, Tréfouel et bien d'autres encore, vous vous inquiéteriez : c'est qu'il y a donc là quelque chose de sérieux.

## A PROPOS DE MANCHESTER

De tout à fait sérieux : le gain de quelques centaines de milliers d'heures par an sur les horaires dévolues à l'orthographe et à la grammaire dans l'enseignement primaire et même secondaire. Le rayonnement universel de la langue française. Et la vie de celle-ci.

Un humoriste a dit une fois que la langue anglaise avait pour lui ceci de mystérieux : c'est qu'on écrivait **Manchester** et qu'on prononçait Liverpool. Pour offrir un flanc moins large à l'ironie, la langue française présente elle aussi quelques mystères gênants. Ainsi, justement, le mot « orthographe », dont l'écriture est inutilement alourdie, puisqu'il se prononce simplement « ortograf ». Ainsi les mots **legs, remords, suspect, pied, deuxième, orchidée** que l'on prononce **lè, remor, suspé. pié, deuzième, orkidé** et non **legz remordz, suspekt, piède, deucksième** et **orshidéeu**.

Langue logique par excellence, le français comporte quelques absurdités mémorables pour les potaches, embarrassantes pour les autres. L'on écrit, par exemple **miroir** sans **e** muet, mais **observatoire**, avec cet e muet alors que ces deux mots sont des substantifs dérivés de verbes, le miroir servant à se mirer et l'observatoire. . . . à observer. On écrit **factieux** avec un **t** , alors que ce **t** se prononce **c** comme dans **délicieux.** Et **rationnel**, l'un de nos adjectifs favoris prend **deux n** alors que **nationalisme** n'en prend qu'un. Des adjectifs également dérivés de verbes à terminaison **quer** s'écrivent tantôt avec **qu,** comme **manquant** et **communicant. Archevêque** et **archéologue** ont sans doute, dans leur formation, des préfixes différents, mais ils s'écrivent de façon analogue et se prononcent différemment. Alors que **phantasme** et **fantôme** procèdent de la même racine et s'écrivent différemment. **Exiger** et **obliger** ont tous deux produit des substantifs dont le premier, logiquement, s'écrit exigence, alors que le second a été doté d'un **a** adventice, **obligeance**, que rien n'impose, ni le sens ni la prononciation

On pourrait multiplier à l'infini de tels exemples. Que signifient-ils ? Qu'une langue ne se développe pas nécessairement comme une formule algébrique et que les mots, comme toutes choses vivantes, ont leurs bizarreries et leur histoire.

## L'OREILLE OU LE DRAPEAU ?

A l'élève affolé dès le seuil de ses études par la brousse des nuances orthographiques, à l'étranger désemparé par le fait que le **chaos** se prononce **kao**, mais que nous faisons généreusement chuinter le **ch** de **Chaource**, petit pays d'où nous vient un excellent fromage, les puristes, les traditionalistes et certains amoureux de la langue française, qui en goûtent les particularismes comme les tastevins se délectent du bouquet de tel cru, opposent cet argument simple : l'usage.

Vous voulez posséder la langue française ? Eh bien, sucez-la au sein maternel. Plongez verticalement à travers les couches de son histoire, de Rabelais à Gide, sans oublier ni Ronsard, ni Scève, ni du Ballay, ni Racine, ni Flaubert, ni Michelet, ni Rimbaud, ni Mallarmé, ni Valéry,